ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧ អនក្រ.សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភាសំរាប់នីតិកាលទី៣

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

ប្រការ១ : បង្កើតគណៈកម្មការមួយ ដើម្បីកំណត់អាសនៈរដ្ឋសភាសំរាប់នីតិកាលទី៣ និងធ្វើការបែងចែកអាសនៈតាមខេត្ត -ក្រុង ដែលរួមមានសមាសភាពដូចខាងក្រោម :

- តំណាងមួយរូបមកពីគណបក្សប្រជាជនកម្ពុជា
- តំណាងមួយរូបមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច
- តំណាងមួយរូបមកពីគណបក្សសមរង្ស៊ី
- តំណាងពីររូបមកពីក្រសួងមហាផ្ទៃ
- នាយកនៃវិទ្យាស្ថានជាតិស្ថិតិ

ប្រការ២ : គណៈកម្មការកំណត់អាសនៈរដ្ឋសភាសំរាប់នីតិកាលទី៣ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប ដែលជ្រើសតាំងពីក្នុងចំណោមសមាជិកគណៈកម្មការ ដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាត ពីសមាជិកគណៈកម្មការ ។

www.pheakdeylaw.com

ប្រការ៣ : សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទំនាក់ទំនងជាមួយ គណបក្សនយោបាយ ក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មការនេះ អោយផ្តល់ឈ្មោះតំណាងជាក់ស្តែង និង ជាអ្នកកោះប្រជុំលើកទី១ របស់គណៈកម្មការ ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការ តាមគោលការណ៍ដែលបានកំណត់ក្នុងប្រការ២នៃសេចក្តីសំរេចនេះ ។

ប្រការ៤ : គណៈកម្មការនេះមានភារកិច្ច :

- គណនារកចំនួនអាសនៈថ្មីរបស់រដ្ឋសភា តាមរូបមន្តដែលកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ធ្វើសេចក្តីរាយការណ៍ និងលើកសំណើអំពីការបន្ថែមចំនួនអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែលជូនរាជរដ្ឋាភិបាល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាព ភូមិសាស្ត្រ សង្គម និង សេដ្ឋកិច្ច ។

ប្រការ៥ : គណៈកម្មការនេះត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការ ។

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ក្នុងការអនុវត្តន៍ការងារ គណៈកម្មការអាចកំណត់របៀបរបបការងាររបស់ខ្លួនអោយជាក់ស្តែងបន្ថែមទៀតបាន ។

ប្រការ៦ : មធ្យោបាយ សំភារៈ ថវិកា សំរាប់បំពេញការងាររបស់គណៈកម្មការ ជាបន្ទុករបស់រាជរដ្ឋាភិបាល ។

ប្រការ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង រដ្ឋលេខាធិការដ្ឋានដែលពាក់ព័ន្ធ និង គ្រប់សមាសភាព ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និង ប្រការ ៧ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ ។

www.pheakdeylaw.com